ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែមេសា ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែមេសា ឆ្នាំ២០១៧នេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំង និងការងារប្រមូលផលដំណាំរដូវប្រាំងបានបញ្ចប់ជាស្ថាពរហើយ ជាពិសេសការបង្កបង្កើនផលស្រូវរដូវប្រាំងរួមទាំងដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មផងដែរ។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មគឺមាននិន្នាការកើនឡើង ៩១,១៧% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន ៨,៨៣%។ ដោយសារមានភ្លៀងធ្លាក់ច្រើននៅតាមបណ្តាខេត្តនានាក្នុងទូទាំងប្រទេស ការងារបង្កបង្កើនផលស្រូវរដូវវស្សារួមទាំងដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មក៏បានចាប់ផ្តើមយ៉ាងសកម្មនិងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ផងដែរបើប្រៀបធៀបនឹងឆ្នាំមុន។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្មដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះក៏បានទទួលជួបសវនាការជាមួយអង្គទូត និងដៃគូអភិវឌ្ឍន៍នានាតាមវិស័យនីមួយៗរួមទាំងការចូលរួមកិច្ចប្រជុំសំខាន់ៗ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលផ្សេងៗទាំងក្នុង និងក្រៅប្រទេសជាច្រើនផងដែរ។ ជាមួយនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរៀបចំធ្វើសន្និបាតបូកសរុប និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ និងកិច្ចសហការក្នុងការរៀបចំព្រះរាជពិធីច្រត់ព្រះនង្គ័លតាមប្រពៃណីនាខែពិសាខដើមឆ្នាំនេះ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែមេសា ឆ្នាំ២០១៧នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលបញ្ចប់ដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៥៧៦ ៦៤០ហ.ត លើសឆ្នាំមុនចំនួន ៤២ ៨៦២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៤ ១៩៧ហ.ត ស្មើនឹង២,៤៦% និងដោយគ្រឿងយន្តកសិកម្មមានចំនួន ៥៦២ ៤៤៣ហ.ត ស្មើនឹង៩៧,៥៤%


អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- ផ្ទៃដីសាបសម្រេចបានចំនួន ៥៥៦ហ.ត តិចជាងឆ្នាំមុនចំនួន ៦០៧ហ.ត
- ផ្ទៃដីសន្ទូង និងព្រោះសម្រេចបានចំនួន ៥១៨ ៥៧៤ហ.ត ស្មើនឹង ១១៩,៥៥% នៃផែនការ ៤៣៣ ៧៥៥ហ.ត លើសឆ្នាំមុនចំនួន ២៩ ១១៩ហ.ត
- ការងារប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៥១៨ ៥១៤ហ.ត ស្មើនឹង៩៩,៩៩% លើផ្ទៃដីអនុវត្តចំនួន ៥១៨ ៥៧៤ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ២ ៣១៥ ៣៦៤តោន លើសឆ្នាំមុន ១៥០ ៧៦៤ តោន។ ទិន្នផលគិតជាមធ្យមទទួលបាន ៤,៤៦៥តោន/ហ.ត លើសឆ្នាំមុន ៤៣គ.ក្រ/ហ.ត។

**១.២ លទ្ធផលបញ្ចប់ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំង**

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១១២ ២៣០ហ.ត តិចជាងឆ្នាំមុនចំនួន ៧ ០៧០ ហ.ត ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៩៧ ៤៦៧ហ.ត ស្មើនឹង ១២១,០៩% នៃផែនការ ៨០ ៤៩៤ហ.ត លើសឆ្នាំមុនចំនួន ៧ ០០១ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១៤ ៧៦៣ហ.ត ស្មើនឹង ១០៣,៨៩% នៃផែនការ ១៤ ២១០ហ.ត តិចជាងឆ្នាំមុនចំនួន ៦៩ហ.ត។

**១.៣ ផលិតកម្មដំណាំស្រូវរដូវវស្សាឆ្នាំ២០១៧**

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ១៨៦ ០៥៣ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១ ៣៩៣ហ.ត និងដោយគ្រឿងយន្តកសិកម្មមានចំនួន ១៨៤ ៦៦០ហ.ត លើសឆ្នាំមុន ១៥៣ ៩៤៦ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ០៩ហ.ត
- ផ្ទៃដីសន្ទូង និងព្រោះសម្រេចបានចំនួន ៥៦ ១៦៩ហ.ត ស្មើនឹង២,២៥% នៃផែនការ ២ ៤៩៣ ៦៩០ហ.ត លើសឆ្នាំមុនចំនួន ៣០ ៦៤៦ហ.ត

**១.៤ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវវស្សា**

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៥១ ៥៤៣ហ.ត លើសឆ្នាំមុនចំនួន ៥០ ៧៩៧ ហ.ត ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៤៤ ៦៩៧ហ.ត ស្មើនឹង ៦,៣០% នៃផែនការ ៧០៩ ០៦០ហ.ត លើសឆ្នាំមុនចំនួន ៤៤ ១៦២ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៦ ៨៤៦ហ.ត ស្មើនឹង ៦,១៤% នៃផែនការ ១១១ ៤៤០ហ.ត លើសឆ្នាំមុនចំនួន ៦ ៦៣៥ហ.ត។

**១.៥ ការនាំចេញអង្ករ**

ក្នុងខែមេសា ឆ្នាំ២០១៧នេះ ការនាំអង្ករចេញតាមរយៈច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ៤៥ ៧១៦ តោន ដែលមានការកើនឡើងចំនួន ៦ ១៦៦តោន (+១៥,៦០%) ធៀបនឹងបរិមាណនាំចេញក្នុងខែមេសា ឆ្នាំ២០១៦។ ក្នុងខែមេសានេះ យើងបាននាំចេញទៅកាន់ទិសដៅចំនួន ៥៥ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (៨១ ៤៣២តោន) ប្រទេសបារាំងឈរលំដាប់ទី២ (២៧ ៨៤៨តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (១៦ ៧០៣តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៤ (១៥ ២៥៩តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (៩ ៧០៦តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៦ (៧ ៤៤០តោន) ប្រទេសឆែកឈរលំដាប់ទី៧ (៧ ៣៦១តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៨ (៤ ៨៧៨តោន) ប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី៩ (៤ ៥៩១តោន) និងប្រទេសអេស្ប៉ាញឈរលំដាប់ទី១០(២ ៥៥០តោន)។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៧១ក្រុមហ៊ុន។ ទន្ទឹមនឹងនេះ ក្រសួងក៏បានចេញសេចក្តីណែនាំលេខ២៦៤៥ កសក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការបញ្ឈប់ការនាំចូល ផ្គត់ផ្គង់ចែកចាយ និងប្រើប្រាស់ថ្នាំកសិកម្ម ដែលមានសារធាតុសកម្ម Tricyclazole។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបាន ប្រចាំខែនេះ (តោន) | បញ្ចេញលក់ ប្រចាំខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥៨៣ | ៧៧៦ | ២៥៩ | ៨៤ |
| | **សរុប I** | **៥៨៣** | **៧៧៦** | **២៥៩** | **៨៤** |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១ ៩៣៤ | ១៥ ៣៥៩ | ១ ៤០៥ | ៦៩៦ |
| ២ | ក្រុមហ៊ុន ស៊ីហ្វ៉ាប់ប៊េីលីមីធីត (រតនគីរី) | ៧៩ | ២ ៥៥៨ | ៩៦៩ | ៩៣៦ |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១ ០១០ | ២ ១២១ | ១៩ | - |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ១១០ | ៥៦៣៤ | ២៣២ | ១៧០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣ ៩៩៧ | ៨ ៦៦១ | ៧០៣ | ៦២៨ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វរីសសស៍ (ស្នួល) | ២ ៦២៨ | ៤ ៤០៦ | ២៩០ | ៣២០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៨៨២ | ៣ ៣៩០ | ៨ ៤២១ | ៦ ៥៣៤ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣២៧ | ៥ ៩២៤ | ១ ០៧៤ | ១ ០០៨ |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៤ ០៣៥ | ៥ ៧៣១ | ៧ ៣២០ | ៦ ៨០០ |
| | **សរុប II** | **៣២ ០០២** | **៥៣ ៧៨៤** | **២០ ៤៣៣** | **១៧ ០៩២** |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៨ ៩៦០ | ២២៣ ៧៥៨ | ២១ ៣០០ | ៨ ៨០០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៨៦ ៣៣១ | ១៥៤ ៤៥៤ | ២៤ ៩០០ | ១៥ ២០០ |
| | **សរុប III** | **៩៥ ២៩១** | **៣៧៨ ២១២** | **៤៦ ២០០** | **២៤ ០០០** |
| | **សរុប I+II+III** | **១២៧ ៨៧៦** | **៤៣២ ៧៧២** | **៦៦ ៩៣២** | **៤១ ១៧៧** |

- គួរកត់សម្គាល់ថា សម្រាប់ខែមេសា ឆ្នាំ២០១៧នេះ តម្លៃកៅស៊ូជាមធ្យម ២ ០២៨ដុល្លារក្នុងមួយតោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូស្តីពី ការគ្រប់គ្រងច្បារពូជនិងថ្នាលបណ្តុះកូនកៅស៊ូដល់ប្រជាកសិករនៅខេត្តត្បូងឃ្មុំ
- ត្រួតពិនិត្យទូទៅលើការថែទាំច្បារពូជកៅស៊ូ និងស្រង់ទិន្នន័យជ័រកៅស៊ូឡូត៍ពិសោធន៍ IRAA01-IRAA02
- បានវាស់ទំហំដើមដើម្បីតាមដានការលូតលាស់លើចម្ការពិសោធន៍នីមួយៗ
- បានលាបថ្នាំរំញោចចម្ការពិសោធន៍ IRAE09,IRAE10, IRAE17, IRAE18
- បានស្រាយបង់បំបៅនៅថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០១៦-២០១៧
- បានរៀបចំកូនកៅស៊ូធ៍គ្រសម្រាប់ដាំដុះក្នុងឆ្នាំ២០១៧
- បានថែទាំសមូហកម្មពូជដំណាំគម្របដីចំនួន ១៧ប្រភេទ និងថ្នាលបណ្តុះកូនកៅស៊ូ
- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន ១៥ភាគសំណាក សម្រាប់ធ្វើតេស្តត្រួតពិនិត្យគុណភាពរោងចក្រ
- បានសហការជាមួយអង្គការ UNIDO ដើម្បីពិនិត្យស្ថានភាពឧបករណ៍ជំនួយ
- វិភាគ DRC តាមមេត្រូឡាក់  តាមការជុតរក TSC និងការវិភាគតាមមន្ទីរពិសោធន៍
- បានផ្គត់ផ្គង់អង្ករ ទឹក អគ្គិសនី និងបៀវត្សរ៍ជូនកម្មករចៀរជ័របានទាន់ពេលវេលា។

### ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានបើកកិច្ចប្រជុំពិភាក្សាស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួល កិច្ចសន្យាផលិតកម្មកសិកម្មដោយមានការចូលរួមពីបណ្តាក្រសួងពាក់ព័ន្ធ និងវិស័យឯកជននានា

- បានរៀបចំគម្រោងចំនួន ០២៖(១)ស្តីពីការសិក្សាស្រាវជ្រាវ និងវាយតម្លៃលើគុណភាព និងសុវត្ថិភាពនៃផលិតផលធញ្ញជាតិ (Research Study and Evaluation on Quality and Safety of Cereal and Grain Commodities) (២) ស្តីពីការគ្រោងចំណាយក្នុងការវិភាគរកកាកសំណល់ Tricyclazole ក្នុងស្រូវនិងអង្ករកម្ពុជា

- បានចូលរួមប្រជុំពិភាក្សាតាមប្រព័ន្ធស្ពាយពីប្រទេសហ្វីលីពីនរវាងក្រុមការងារអន្តរក្រសួងសុវត្ថិភាពចំណីអាហារនៅក្រសួងសុខាភិបាលស្តីពី ការលើកគម្រោងផែនការសកម្មភាពសម្រាប់ឆ្នាំ ២០១៨

- បានចូលរួមសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការអនុវត្តស្តង់ដារលើការឆ្លើយតបការផ្ទុះជំងឺដែលកើតឡើងថ្មីៗពីការពុលអាហារនៅខេត្តប៉ៃលិន

- ក្រុមការងារបច្ចេកទេសនៃមន្ទីរពិសោធន៍បានដំឡើងនិងធ្វើតេស្តម៉ាស៊ីនបិទទឹកនិងម៉ាស៊ីនវិភាគឬដកយកអាស៊ីតនុយក្លេអ៊ិច

- បានរៀបចំសេចក្តីព្រាងប្រកាសនិងបានពិភាក្សាស្តីពីការចុះបញ្ជីអ្នកប្រមូលទិញផលិតផលកសិកម្មនិងអ្នកដាំដុះអ្នកចិញ្ចឹមសត្វ និងអ្នកកែច្នៃផលិតផលកសិកម្ម។

### ៤ ផ្នែកផលិតកម្ម និងបសុពេទ្យ

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព។ (ខ) ការងារឡជីវឧស្ម័នបន្តចុះអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វនិងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ (គ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្ទួនដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង CIAT។

**៤.២ ការងារបសុពេទ្យ**

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** ក្នុងខែមេសា ឆ្នាំ២០១៧ នេះ រាជធានី-ខេត្តចំនួន០៩ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១ ៧៤៤លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទូទាំងប្រទេសបានចំនួន ០៧ករណី សត្វចំនួន ១៣ក្បាល ដោយបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ៤១៨,៣គីឡូក្រាម និងផាកពិន័យ ៩លានរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនសត្វរស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត។ រហូតមកទល់ពេលនេះសត្តឃាតដ្ឋានទទួលបានគោលការណ៍អនុវត្តចំនួន ១៥៥កន្លែង និងបានចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស ដើម្បីសុខុមាលភាពសាធារណៈ។

- **ការងារនីតិកម្មនិងវិវាទ៖** កំពុងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វទៅតាមលំដាប់អាទិភាពមានជាអាទិ៍៖ សេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងគ្រប់គ្រងសត្តឃាតដ្ឋាន ព្រមទាំងបានប្រជុំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បី

រៀបចំចងក្រងអនុក្រឹត្យ និងសៀវភៅសម្រាប់ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត។

### ៤.៣ ការងារស្រាវជ្រាវ៖

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋាន ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្ដាសាយបក្សី។ ជាក់ស្ដែងក្នុងខែមេសា ឆ្នាំ២០១៧នេះ វិទ្យាស្ថានបានពិនិត្យវត្ថុវិភាគសរុបចំនួន ២៧៤វត្ថុវិភាគ។

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១១៤ក្បាល ក្នុងនោះគោបា១ក្បាល គោប្រាម៉ាន់កាត់៦ក្បាល គោជំទង់៣៨ក្បាល គោបៅដោះ៣០ក្បាល គោកំផែង-សែន៣៩ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ២៦១ក្បាល ក្នុងនោះជ្រូកបា៩ក្បាល ជ្រូកមេ៦០ក្បាល កូនជ្រូក៧៨ក្បាល កូនជ្រូកលក់៨៥ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្ដី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្ដាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ រួមទាំងពង្រឹងយន្តការផ្សព្វផ្សាយតាមរយៈភ្នាក់ងារសុខភាពសត្វភូមិ។

## ៥ ផ្នែកព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- បានវិភាគទិន្នន័យ និងផ្ទៀងផ្ទាត់ព័ត៌មានសារពើភ័ណ្ឌព្រៃសហគមន៍ ដោយមានការចូលរួមពីរដ្ឋបាលព្រៃឈើ អាជ្ញាធរភូមិ-ឃុំ គណៈកម្មការគ្រប់គ្រង សហគមន៍ព្រៃឈើ និងសមាជិកសហគមន៍ព្រៃឈើ

- បានចុះបើកវគ្គផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ការគ្រប់គ្រង និងការអនុវត្តលិខិតបទដ្ឋានច្បាប់ សហគមន៍ព្រៃឈើ ផលប្រយោជន៍ព្រៃសហគមន៍ និងនីតិវិធីទប់ស្កាត់បទល្មើសព្រៃសហគមន៍ចំនួន ០២ វគ្គ ជូនដល់សហគមន៍ព្រៃឈើចំនួន ០២កន្លែង ដែលស្ថិតនៅក្នុងខេត្តស្វាយរៀងរួមមាន៖ សហគមន៍ព្រៃឈើភូមិព្រៃផ្ការ និងភូមិតាញ៉យ ស្ថិតក្នុងឃុំសំឡី និងឃុំខ្សែត ស្រុកកំពង់រោទិ៍

- បានចុះតាមដាន ត្រួតពិនិត្យការងារសហគមន៍ព្រៃឈើក្នុងខេត្តកំពង់ធំចំនួន ១៦សហគមន៍ និងនៅក្នុងខេត្តសៀមរាបចំនួន ០៨សហគមន៍

- បានផ្ដល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តនិងយានយន្តជូនដល់ក្រុមហ៊ុន និងអតិថិជនសរុបចំនួន ០៣ គ្រឿង

- បានផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ០៥ និងអតិថិជនចំនួន ០១រូប មានឈើហ៊ុបមូលចំនួន ៥ ៥៨៩ម៣ ឈើអារចំនួន ៣៩៤ម៣ ឈើជ្រុងចំនួន ៣៩ម៣ កូនក្រឡឹងចំនួន ៥៩៨ម៣ កូនឈើចំនួន ៧៣ ០១៧ដើម អុសចម្រុះចំនួន ២២ ៤០០ស្ទែរ និងជ័រទឹកចំនួន ៨០តោន។

### ៥.២ ការងារអភិរក្សសត្វព្រៃ

- បានបំពាក់ម៉ាស៊ីនថតស្វ័យប្រវត្តិ នៅតំបន់មានវត្តមានដំរីព្រៃនៅថ្មបាំង អារ៉ែង វាលតាភូ និងអូរកី នៃខេត្តកោះកុង បានសរុបចំនួន ៤២គ្រឿង។ ការវិភាគរូបថត និងវីដេអូបានមកពីម៉ាស៊ីនថតស្វ័យប្រវត្តិទាំង ១៨ គ្រឿង នៅក្នុង ១៨ ទីតាំង បានបង្ហាញថាវត្តមានដំរីទោលដើរតែឯងចំនួន ០៨ ក្បាលផ្សេងៗគ្នាត្រូវបានថត នៅក្នុងចំណោមនេះមានដំរីជំទង់ ០១ ក្បាល មានរបួសធ្ងន់ធ្ងរជិតដាច់ប្រម៉ោយផ្នែកខាងចុងព្រមទាំងមាន រូបរាងស្គមស្បែកជ្រីវជ្រួញដែលបង្ហាញអំពីកង្វះខាតអាហារ ចំណែកឯដំរីផ្សេងទៀតមានសុខភាពល្អប្រសើរ

- ចុះអនុវត្តសកម្មភាពទីគម្រង់ត្មាតបាន ០១ លើកនៅក្នុងតំបន់គម្រោង ចាប់ពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៧ ជាលទ្ធផលបានឃើញមានវត្តមានសត្វត្មាតសរុបចំនួន ១៧ ក្បាល ក្នុងនោះ សត្វត្មាតប្រជេះចំនួន ១២ ក្បាល ត្មាតភ្លើងចំនួន ០៤ ក្បាល និងត្មាតត្នោតចំនួន ០១ ក្បាល

- ដំរីឈ្មោលចំនួន ០១ ក្បាល បានស្លាប់នាថ្ងៃទី២១ ខែមីនា ដោយសារឆក់ចរន្តអគ្គិសនីតង់ស្យុងខ្ពស់ក្នុង ចម្ការធុរេនស្ថិតនៅក្នុងភូមិស្ទឹងប្រាល ឃុំអូរបាក់រទេះ ស្រុកកំពង់សិលា ខេត្តព្រះសីហនុ នៅត្រង់ចំណុចនិយាមកា(១២៣៧០៤២, ៣៩៣៨៨៦)ដោយសារដំរីមួយក្រុមប្រមាណ ០៤ ក្បាលបានចូលក្នុងចម្ការធុរេនបានត្រដុសបង្គោលខ្សែកាបបញ្ជូនតង់ស្យុងខ្ពស់ពីវារីអគ្គិសនីគីរីរម្យពីរ ទៅភ្នំពេញ នៅក្នុងចម្កាសបណ្តាល ឲ្យបង្គោលភ្លើងដួលរលំឆក់ដំរីស្លាប់ ០១ ក្បាល។

## ៥.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ០៦ បានគ្រប់គ្រងកសិដ្ឋានចំនួន ០៧ មានស្វាក្តាមសរុបចំនួន ៥១ ៤៦៧ ក្បាល ហើយក្នុងនោះកូនកើតក្នុងខែមានចំនួន ១ ១៤៥ក្បាល។ ក្នុងខែមេសានេះចំនួនសត្វស្វាក្តាមនាំចេញសរុបមានចំនួន ៣០៥ ក្បាល

- សម្រាប់ខែមេសា ឆ្នាំ២០១៧នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៣២៤ក្បាល (បក្សី៥១ប្រភេទ ថនិកសត្វ ៤៦ប្រភេទ និងល្មូន ១៣ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ៧៦ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ២៥ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៥២ក្បាល ជួសជុលផ្លូវលុបសម្កុកមាន់ និងក្រាលក្រួសក្រហមបានប្រវែង ១ ៤៥០ម និងកាប់ឆ្ការអនាម័យព្រៃបានទំហំ ៣,៥ ហ.ត។ ដោយឡែកគម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិ អន្តរជាតិ ក្រុមល្បាតសហគមន៍ចំនួន ៣០ នាក់ បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ០៥ គឺៈនៅអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) និងបានតាមដានក្រពើលែង ដោយឧបករណ៍ (Radio-tracking) បានជួបប្រទះក្រពើភ្នំផ្ទាល់ចំនួន ០២ ក្បាល។ ធ្វើការពិនិត្យតាមដាននៅតំបន់អភិរក្សដោយបានជួបប្រទះក្រពើភ្នំផ្ទាល់ចំនួន ១២ក្បាល ស្លាកស្នាម ១៧កន្លែង និងលាមកចំនួន ៣៨ដុំ បានលែងក្រពើភ្នំចំនួន ០៦ក្បាលនៅស្ទឹងកំពង់តាជ័យ ខេត្តកោះកុង ចែកប្រដាប់ក្មេងលេង ២០ឈុត និងសៀវភៅរឿងនិទានពីបរិស្ថានចំនួន ០៧ក្បាល ដល់សាលាបឋមសិក្សាភូមិពោធិបឹង។

## ៥.៤ ការងារដាំដើមឈើ

- ការចុះសិក្សាស្រាវជ្រាវ និងធ្វើសារពើភ័ណ្ឌទីតាំងដីសម្រាប់ការងារដាំឈើ
- ការងារថែទាំចម្ការឈើចាស់
- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ៣១ ០៨០ដើម និងចែកជូនប្រជាពលរដ្ឋចំនួន ៣ ៩៨២ដើម
- បានឈូសសម្អាត និងភ្ជួរលើផ្ទៃដីទំហំ ១០ហ.ត និងរៀបចំហេដ្ឋារចនាសម្ព័ន្ធដូចជាៈ ផ្លូវមេចំនួន ០១ខ្សែ និងផ្លូវរងចំនួន ០៥ខ្សែ នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើទួលព្រេច ដើម្បីត្រៀមសម្រាប់រៀបចំនូវពិធីបុណ្យ រុក្ខទិវាថ្នាក់ជាតិ ០៩ កក្កដា ឆ្នាំ២០១៧
- ក្រុមហ៊ុន ស៊ីងបាយ អូរចេក បានរៀបចំសម្អាតផ្ទៃដីចំនួន ៣០ហ.ត សម្រាប់ដាំដុះកូនឈើនៅដើមរដូវវស្សាខាងមុខនេះ។

## ៥.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ចុះពិនិត្យដល់ទីតាំងជាក់ស្តែងតាមលក្ខណៈបច្ចេកទេសចំពោះក្រុមហ៊ុនចំនួន ០២ៈ ក្រុមហ៊ុន ញូ វី ហ្សិន៨៦ និងក្រុមហ៊ុន យូ ស្រ៊ូយ ដែលស្នើសុំបន្តសុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើ និងក្រុមហ៊ុនចំនួន ០១ គឺៈ ក្រុមហ៊ុនវត្ថុសម្បត្តិ ដែលបានស្នើសុំបង្កើតរោងម៉ាស៊ីនអារ-កែច្នៃឈើ

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលរានទេវតាជូនក្រុមហ៊ុនចំនួន ០៣ និងឈើកែច្នៃទៅក្រៅប្រទេសមានបរិមាណសរុបចំនួន ១ ២៦៧ម³ ក្រុមហ៊ុនចំនួន០៤ បាននាំចូលឈើ Radiata MDFUmbila និងCHANFUTA ពីប្រទេសកូរ៉េ មូហ្សាំបិក នីហ្សេរីយ៉ា និងប្រទេសញូហ្ស៊ីលែន មានបរិមាណសរុប ៨០៨ម³

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផល អនុផលព្រៃឈើចំនួន ០៣ ក្រុមហ៊ុន មានបរិមាណឈើកែច្នៃចំនួន ២៥៦ម៣ និងជ័រទឹកចំនួន ២៣តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលចំនួន ០២ ក្រុមហ៊ុន មានបរិមាណផលិតផលឈើកែច្នៃចំនួន ១ ០២៧ម៣

- ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលព្រៃឈើចំនួន ១០រូប បានទៅចូលរួមកិច្ចប្រជុំចំនួន ០៣ លើក និងសិក្ខាសាលាចំនួន ០៤ លើក។

### ៥.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែមេសា ឆ្នាំ២០១៧នេះ ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើសរុបចំនួន៣ ១៥០ ២៨៦ ៥៥៧រៀល និងចំណូលពីសេវាសាធារណៈចំនួន ៤៨៧ ៧៨៨ ១៧៧រៀល និង១៩ ៧៣៤,៩៨ដុល្លារអាមេរិក។

### ៥.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែមេសា ឆ្នាំ២០១៧នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ១០៧ករណី ដោយបញ្ជូនទៅតុលាការចំនួន ៦១ករណីនិងពិន័យអន្តរការណ៍ចំនួន ៤៦ករណី

- ដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន ១២៨ម៣ ឈើអារចំនួន ២១០ម៣ ឈើគ្រាក់ក្រញូងចំនួន ០៥ម៣ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ១ ១៥៥ក្បាល និង១៦៥គ.ក្រ អនុផលព្រៃឈើនិងសម្ភារផ្សេងៗមួយចំនួនទៀត និងសំណុំរឿងបទល្មើសកាប់រានដីព្រៃចំនួន ០១ករណី មានផ្ទៃដីព្រៃឈើដែលកាប់រានចំនួន ០៨ហ.ត ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី និងចុះពង្រឹងការអនុវត្តច្បាប់ចំនួន ១២លើក

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៦ ផ្នែកជលផល

### ៦.១ អាជីវកម្មនេសាទ

#### ៦.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម អនុវត្តបានចំនួន ៤ ៩៤៥តោន ស្មើនឹង៤១,២១% នៃផែនការ ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣ ៨៩៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ២០ ៥០០តោន សរុបរយៈពេល៤ខែបានចំនួន ៩០ ៤៥០តោន ស្មើនឹង២៦,២៩% នៃផែនការ ៣៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ២ ៤០៥តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន ៣ ៥០០តោន សរុបរយៈពេល៤ខែបានចំនួន ២៣ ០០០តោន ស្មើនឹង១៥,៩៧% នៃផែនការ ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ២ ០០០តោន។

#### ៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៩ ១០០តោន សរុបរយៈពេល៤ខែបានចំនួន ៣៤ ៤២៥តោន ស្មើនឹង៣១,៣០% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ៥៧៥តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន ១៤ ៤៧៥តោន សរុបរយៈពេល៤ខែបានចំនួន ៤៤ ៤៥៣តោន ស្មើនឹង២៥,៧៣% នៃផែនការ ២០៧ ៣៦០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៤ ៤០៣តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ១១ ០០០ក្បាល សរុបរយៈពេល៤ខែបានចំនួន ៣៨ ៥០០តោន ស្មើនឹង១៥,៤០% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១៥០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួនប្រមាណ ៥០០ ០០០កូន សរុបរយៈពេល៤ខែបានចំនួន ៤៥ ៣០០ ០០០តោន ស្មើនឹង២៥,១៧% នៃផែនការ ២០០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួនប្រមាណ ៧ ៣០០ ០០០កូន។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ អនុវត្តបានចំនួន ២ ៦៥០តោន សរុបរយៈពេល៤ខែបានចំនួន ២០ ០០០តោន ស្មើនឹង២៤,៣៩% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ៣៧០តោន សរុបរយៈពេល៤ខែបានចំនួន ៣ ៩០០តោន ស្មើនឹង៤៨,៧៥% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៤២៥តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៦ ៩០០ ០០០លីត្រ សរុបរយៈពេល៤ខែបានចំនួន ១៧ ៨០០ ០០០លីត្រ ស្មើនឹង ៣៥,៦០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣០០ ០០០លីត្រ។

### ៦.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន ៨៥០តោន សរុបរយៈពេល៤ខែបានចំនួន ៣ ៣៨០តោន ស្មើនឹង ២២,៥៣% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ៣០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន ៥០០តោន សរុបរយៈពេល៤ខែបានចំនួន ១ ៨៧០តោន ស្មើនឹង៣៧,៤០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ១៨០តោន។

### ៦.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សម្រាប់ខែមេសា ឆ្នាំ២០១៧នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ២០៥ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២០១ករណី និងសមុទ្រចំនួន ៤ករណី

- គួរកត់សម្គាល់ថា ក្នុងការចុះបង្ក្រាបបទល្មើសនេសាទនៅជុំវិញបឹងទន្លេសាបគឺមានការអញ្ជើញចូលរួមចុះត្រួតពិនិត្យផ្ទាល់យ៉ាងសកម្មពី សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រួមទាំងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៦.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផលខែមេសា ឆ្នាំ២០១៧ ចំនួន ៩២ ៩៦០ ៤០០ រៀល សរុបរយៈពេល៤ខែបានចំនួន ៩២២ ២៥៥ ៤០០រៀល ស្មើនឹង៣០,៧៤% នៃផែនការ ៣ ១៨២ ១២៥ ៤០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៣៨២ ០០៦ ៦៦០រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចុះតាមដាននិងត្រួតពិនិត្យពិសោធន៍ នៅខេត្តកំពត
- បានចុះត្រួតពិនិត្យនិងវាស់វែងទិន្នន័យពិសោធន៍ ដែលប្រព្រឹត្តទៅនៅខេត្តសៀមរាប
- បានចុះប្រមូលទិន្នន័យស្តីពីការសាយភាយពូជស្រូវនិងការប្រើប្រាស់បច្ចេកទេសកសិកម្ម នៅខេត្តបាត់ដំបង និងបន្ទាយមានជ័យ
- បានចុះរៀបចំការងារពិសោធន៍ស្រាវជ្រាវលើដំណាំបន្លែ ដែលប្រព្រឹត្តទៅនៅខេត្តស្វាយរៀងនិងត្បូងឃ្មុំ
- បានចុះធ្វើទិវាស្រែបង្ហាញលើដំណាំផៃថាវ មានអ្នកចូលរួមសរុបចំនួន៦២នាក់ ដែលប្រព្រឹត្តទៅនៅខេត្តតាកែវ
- បានចុះរៀបចំដាំដុះដំណាំសម្រាប់ស្រែបង្ហាញដើមរដូវវស្សានិងធ្វើការកំណត់ទីតាំងពិសោធន៍ នៅខេត្តតាកែវ
- បានចុះប្រមូលសំណាកផ្លែស្វាយ នៅខេត្តកំពង់ស្ពឺ
- បានចុះគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់វិទ្យាស្ថាន និងតាមដានការងារពិសោធន៍ នៅខេត្តព្រះវិហារ
- បានចុះជ្រើសរើសទីកន្លែងពិសោធន៍ នៅខេត្តត្បូងឃ្មុំ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ១៤ក្រុមហ៊ុន សរុបចំនួន ១៥៤មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១៧ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០៧ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០៥ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន ០៨ក្រុមហ៊ុនសរុបចំនួន ៥៣សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម ព្រៃវែង និងខេត្តស្វាយរៀង ដែលមានសមាសភាពចូលរួមសរុបចំនួន ១១៧នាក់។

### ៨.៤ ការងារអនុវត្តច្បាប់

- បានធ្វើប្រតិវេទន៍ដល់ក្រុមហ៊ុនចំនួន ០៧ក្រុមហ៊ុន
- ពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៤ ០០០ ០០០រៀល ពីក្រុមហ៊ុនចំនួន ០៣។

## ៩ ផ្នែករដ្ឋបាល

- ក្នុងខែមេសា ឆ្នាំ២០១៧នេះ បានទទួលលិខិតពីក្រសួង-ស្ថាប័ននានាចំនួន ២៦៨ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២៣៣ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៨៧ច្បាប់ និងចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តរដ្ឋបាល
- បញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ០៥៦ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៥៩ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ១២ច្បាប់
- បានចេញប្រកាសព័ត៌មានស្តីពីការទប់ស្កាត់ការនាំចូលជ្រូកពីក្រៅប្រទេសមកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការចិញ្ចឹមជ្រូកក្នុងស្រុក
- បានចេញសេចក្តីជូនដំណឹងស្តីពីការនាំចូលសត្វរស់ សាច់សត្វ និងផលិតផលសត្វដើម្បីផ្គត់ផ្គង់បំពេញតម្រូវការសាច់នៅរាជធានីភ្នំពេញ និងបណ្តាខេត្ត ដើម្បីពង្រឹងការគ្រប់គ្រងហានិភ័យនៃការឆ្លងរាលដាលនៃជំងឺសត្វ លើកកម្ពស់គុណភាពសាច់សត្វ និងការពារសុខភាពសាធារណៈប្រកបដោយសុវត្ថិភាព
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំ ពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អប្រសើរ ការរៀបចំជួបជុំមន្ត្រីរាជការក្នុងពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ការចុះសាកសួរសុខទុក្ខកងទ័ពលេខ ៣០១ ៣០២ ៣០៣ ព្រមទាំងចាត់ចែងផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម) ។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៦៣៧នាក់ ក្នុងនោះនារីចំនួន ១ ៤៦៦នាក់ ស្មើនឹង ២២% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៧៦៤នាក់ ក្នុងនោះនារីចំនួន ៧៦៩នាក់ ស្មើនឹង ២៧%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន ៣ ៨៧៣នាក់ ក្នុងនោះនារីចំនួន ៦៩៧នាក់ ស្មើនឹង ១៧% (បានបញ្ចូលមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ(៩០០នាក់) និងខណ្ឌរដ្ឋបាលជលផល(៥០៥នាក់) ទៅក្នុងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តរួចហើយ)
- បានចេញប្រកាសផ្ទេរមន្ត្រីរាជការក្រៅក្រសួងចំនួន ០២នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងមានចំនួន០៦នាក់
- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកប្រចាំឆ្នាំមានចំនួន០១នាក់ និងច្បាប់សម្រាកមាតុភាពមានចំនួន ០២នាក់
- បានចេញប្រកាសដាក់មន្ត្រីឲ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈមានចំនួន ២០នាក់
- បានពិនិត្យ កែតម្រូវលើការប្រែប្រួលស្ថានភាពរដ្ឋបាលពីខែមករា ដល់ខែឧសភា ឆ្នាំ២០១៧
- បានចេញប្រកាសដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សមានចំនួន ១៤នាក់ ក្នុងនោះនារី០១នាក់
- បានចេញប្រកាសឲ្យមន្ត្រីរាជការ ចូលបម្រើការងារនៅអង្គភាពដើមវិញមានចំនួន ១០នាក់

- មន្ត្រីរាជការបានចូលរួមការងារបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសសរុបមានចំនួន ៥៥នាក់ ក្នុងនោះនារី១៧នាក់។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានធ្វើការប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ២០១៦
- បានធ្វើតារាងវាយតម្លៃអង្គភាពតាមលក្ខខណ្ឌវិនិច្ឆ័យអង្គភាពថវិការបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- បានចេញលិខិតណែនាំឱ្យពង្រឹងការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង
- បានធ្វើផែនការសកម្មភាពលម្អិត និងផែនការថវិកាឆ្នាំ២០១៧ ដើម្បីអនុវត្តសកម្មភាពរួមដំណាក់កាលទី៣នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ១២ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១២.១ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ សរុបចំនួន ៨៧៨នាក់ (ស្ត្រី ៣១២នាក់) ក្នុងនោះ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៦២១នាក់(ស្ត្រី ២១៦នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន ២៥៧នាក់(ស្ត្រី ៩៦នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី
- បានកាប់ព្រៃ ស្ការស្រះ និងពិនិត្យសម្ភារប្រើប្រាស់នៅស្ថានីយពិសោធន៍កសិកម្មត្រាំកក់
- បានដឹកនាំនិស្សិតធ្វើការពិសោធន៍បន្លែ ត្រី និងដំណាំជប៉ុន
- បានបន្តការកែតម្រូវកម្មវិធីសិក្សាឱ្យឆ្លើយតបនឹងទីផ្សារ បទដ្ឋានជាតិ អន្តរជាតិ
- បានបន្តរៀបចំពិសោធន៍ដំណាំស្រូវជប៉ុន និងដំឡូង។

### ១២.២ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៦-២០១៧ សរុបមានចំនួន ៧៨៦នាក់(ស្ត្រី ៣១៨នាក់) រួមមានៈ និស្សិតអាហារូបករណ៍សរុប ៥៧៧នាក់ (ស្ត្រី ២៧១នាក់) និស្សិតសិក្សាបង់ថ្លៃចំនួន ២០៩នាក់ (ស្ត្រី ៤៧នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ ក្នុងនោះកំពុងសហការជាមួយ DTRA ICEBP ដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍
- បានសហការជាមួយអង្គការ OISCA បញ្ជូននិស្សិតជំនាញក្សេត្រសាស្ត្រចំនួន ០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំនៅប្រទេសជប៉ុន
- បានសហការជាមួយទីភ្នាក់ងារ KOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់សាស្ត្រាចារ្យទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសកូរ៉េ
- បានជួបពិភាក្សាជាមួយប្រតិភូសាកលវិទ្យាល័យ វ៉ាស៊ីនតោន ស្តីពីការរៀបចំសិក្សាគម្រោងចិញ្ចឹមគោយកទឹកដោះនៅខេត្តកំពង់ចាម
- បានទទួលជួបតំណាង JICA ពិភាក្សាពីគម្រោងសិក្សាអង្កេតពីភាពរីកចម្រើននៃសហគមន៍កសិកម្ម ដែលមានទីតាំងនៅជុំវិញខេត្តកំពង់ចាម
- បានបន្តសហការជាមួយ DTRA (Defence Threat Reduction Agency) បើកវគ្គបណ្តុះបណ្តាលនិស្សិតជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ
- បានធ្វើការពិសោធន៍ចិញ្ចឹមដង្កូវនាងព្រៃនៅក្នុងមន្ទីរពិសោធន៍
- បានរៀបចំជួសជុលផ្ទះសំណាញ់ដើម្បីរៀបចំធ្វើការពិសោធន៍ Hydroponic
- បន្តពិសោធន៍ចិញ្ចឹមនិងភ្ញាស់ដង្កូវនាងព្រៃ និងបញ្ជូនដង្កូវនាងព្រៃឱ្យសហគមន៍កសិកម្មចិញ្ចឹមចំនួន ១០គ្រួសារ នៅឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

### ១២.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៦-២០១៧ សរុបមានចំនួន ៣ ៦៣៥នាក់ ចែកចេញជា ១០មហាវិទ្យាល័យគឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និង មហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង និងថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្ដុះបណ្ដាលលើកម្មវិធីបរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត
- បានបញ្ជូនថ្នាក់ដឹកនាំមន្ត្រីសាស្ត្រាចារ្យ ចូលរួមកម្មវិធីនានានៅតាមសាកលវិទ្យាល័យដៃគូនៅបរទេសបានចំនួន ០៨នាក់ និងបានបញ្ជូននិស្សិតចូលរួមកម្មវិធីផ្លាស់ប្ដូរនិស្សិតរយៈពេល៦ខែ នៅសាកលវិទ្យាល័យ Tsukuba និង Kagawa នៃប្រទេសជប៉ុនបានចំនួន ០៥នាក់
- បានទទួលសាស្ត្រាចារ្យជប៉ុន និងឆេកចំនួន ០៤នាក់មកបំពេញការងារនៅតាមមហាវិទ្យាល័យជំនាញនានា
- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយសាកលវិទ្យាល័យបរទេសចំនួន៣ គឺ សាកលវិទ្យាល័យ Jung Woon និង College of NRLS, Pusan National University នៃសាធារណរដ្ឋកូរ៉េ និង សាកលវិទ្យាល័យវិទ្យាសាស្ត្រជាតិហាណូយ (University of Science, National University of Vietnam) នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

## IV-សេចក្ដីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបាន ៥១៨ ៥១៤ហ.ត ស្មើនឹង ៩៩.៩៩% នៃផ្ទៃដីអនុវត្តបាន ៥១៨ ៥៧៤ហ.ត។ ដោយឡែក ទិន្នផលស្រូវប្រាំងគិតជាមធ្យមទទួលបានចំនួន ៤,៤៦៥តោន/ហ.ត លើសឆ្នាំមុនចំនួន ៤៣គ.ក្រ/ហ.ត។ ជាមួយនឹងការខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសស្រាក់សស្រាំរបស់បងប្អូនកសិករ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវប្រាំង ដោយគិតគូរទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីមានគ្រោះរាំងស្ងួត ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ រីឯការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២,២៥% មានសភាពលឿនជាងឆ្នាំមុនប្រមាណ ៣០ ៦៤៦ហ.ត។ ជាពិសេសកិច្ចសហការក្នុងការរៀបចំព្រះរាជពិធីច្រត់ព្រះនង្គ័ល មច្ឆទិវា និងរុក្ខទិវាតាមប្រពៃណីនាពេលខាងមុខនេះ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្ដែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានជំរុញគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលាលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឲ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្ដាញសង្គមផ្សេងៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្ដាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។

## V- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវវស្សា និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៧-២០១៨ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំរួមផ្សំផ្សេងទៀតដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងកាត់បន្ថយការប្រើប្រាស់សារធាតុគីមី

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផលរដូវវស្សានេះ

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះថ្លៃកសិផលផ្សេងៗជាយថាហេតុ ការងារសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋានក៏ដូចជាទីផ្សារកសិផលផ្សេងៗទៀតផងដែរ

- យកចិត្តទុកដាក់គិតគូរផ្សព្វផ្សាយអំពីការប្រើប្រាស់ជីកសិកម្ម ថ្នាំកសិកម្ម និងសារធាតុគីមីផ្សេងៗទៅលើផលិតផលកសិកម្មដែលនាំឲ្យប៉ះពាល់សុខុមាលភាពសាធារណៈ និងការនាំចេញកសិផលទៅក្រៅប្រទេស

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

### ២ ផ្នែកផលិតកម្មនិងបសុព្យាបាល :

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្ត-រាជធានី និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ ជាពិសេសការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមតំបន់ដែលខ្សត់ទឹក

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូ

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរិលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើសំខាន់ៗ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ សហគមន៍ព្រៃឈើ និងភាគីពាក់ព័ន្ធនានាជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព

- ត្រៀមរៀបចំទិវាដំណាំឈើ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៩ កក្កដា នាពេលខាងមុខ។

**៤ ផ្នែកជលផល**:

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងគិតគូរអំពីមធ្យោបាយសង្គ្រោះធនធានមច្ឆជាតិនៅពេលឡើងកម្តៅខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃលិចទឹក

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៧ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គាក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោឱ្យបានសមស្របតាមវិធានបច្ចេកទេស ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ

- ចុះពិនិត្យទីតាំងដើម្បីត្រៀមរៀបចំមច្ឆទិវា០១ កក្កដា នាពេលខាងមុខ។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈប្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តសហការរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល ព្រមទាំងជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ផ្សេងៗទៀត លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រតាមការចាំបាច់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទ ការចុះពង្រឹងភារកិច្ចក្នុងការបញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឱ្យស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- ត្រៀមរៀបចំទិវាពិភពលោកប្រយុទ្ធប្រឆាំងនិងរហោស្ថានកម្ម ឬឱនភាពដីដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៧

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍

វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា រួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្មមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម៕

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**